**មាត្រា ៤.-** ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ធ្វើនៅព្រះបរមរាជវាំងរាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

# ព្រះរាជក្រឹត្យ លេខ នស/រកត/០៥០១/១៨០

## ស្តីពី

## ការបង្កើតសេណ្ឋីយដ្ឋានតំព្រះរាជទ្រព្យ

* * *

**យើង**

**ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ**

**រាជហរិវង្ស ឧភតោសុជាត វិសុទ្ធពង្ស អគ្គមហាបុរសរតណ៍**

**និករោត្តម ធម្មិកមហារាជាធិរាជ បរមនាថ បរមបពិត្រ**

**ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៦ ចុះថ្ងៃទី ២៥ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥ ចុះថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់ផ្នែកវប្បធម៌ជាតិ

- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានទ្រង់យល់ក្រឹត្យលេខ ១០០ក្រ ចុះថ្ងៃទី ១៣ ខែ តុលា ឆ្នាំ ១៩៩២ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានទទួលការយល់ព្រមពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០៦

## ត្រាស់បង្គាប់

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

បង្កើត រមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ដែលស្ថិតក្នុងឃុំផ្សារដែក និង ឃុំភ្នំបាត ស្រុកពញាឮ ខេត្តកណ្ដាល ។

**មាត្រា ២.-**

ការបង្កើតរមណីយដ្ឋាននេះ មានគោលបំណង ៖

- អភិរក្សកេរដំណែលបេតិកភណ្ឌ វប្បធម៌ ប្រវត្តិសាស្ត្រជាតិ
- អភិវឌ្ឍតំបន់ទេសចរណ៍
- អភិរក្សបរិស្ថាន វប្បធម៌ ធម្មជាតិ ។

រមណីយដ្ឋាននេះត្រូវបានប្រកាសជាតំបន់បំរើឱ្យផលប្រយោជន៍សាធារណៈ ។

## ជំពូកទី ២
## ការកំណត់តំបន់

**មាត្រា ៣.-**

រមណីយដ្ឋានភ្នំព្រះរាជទ្រព្យនេះមានទំហំ ៥០៨ហិកតា ត្រូវបានបែងចែកជាបីតំបន់ផ្សេងគ្នា ដូចតទៅ :

ក- តំបន់ទី១ គឺជា : តំបន់អភិរក្សបេតិកភណ្ឌប្រវត្តិសាស្ត្រ ហៅថា តំបន់ស្នូល ហើយស្ថិតនៅក្នុងរង្វង់អ័ក្សផ្លូវជុំវិញជើងភ្នំ ដែលមានទំហំ ៧៩ ហិកតា។

ខ- តំបន់ទី២ គឺជា : តំបន់អភិវឌ្ឍសេដ្ឋកិច្ចទេសចរណ៍ហៅថា តំបន់ទ្រនាប់ ហើយស្ថិតក្នុងចន្លោះព្រំប្រទល់ អ័ក្សផ្លូវជុំវិញជើងភ្នំ និងខ្សែបន្ទាត់ព្រំប្រទល់ a,b,c,d...,m ដែលមានទំហំ ២១៧ ហិកតា។

គ- តំបន់ទី៣ គឺជា : តំបន់អភិរក្ស និងថែរក្សាការពារបរិស្ថានធម្មជាតិ ហៅថា តំបន់រណប ហើយស្ថិតនៅចន្លោះខ្សែបន្ទាត់ព្រំប្រទល់ a,b,c,d...,m និងខ្សែបន្ទាត់ព្រំប្រទល់ A,B,C,D...,L ដែលមានទំហំ ២១២ ហិកតា។

និយាមការនៃចំណុច ខ្សែបន្ទាត់ព្រំប្រទល់ a,b,c,d...,e,f,g,h,i,j,k,l,m និង ខ្សែបន្ទាត់ព្រំប្រទល់ A,B,C,D,E,F,G,H,I,J,K,L មាននៅក្នុងឧបសម្ព័ន្ធទី១ និងឧបសម្ព័ន្ធទី២។

**មាត្រា ៤.-**

របបបទ និងនីតិវិធីនៃការគ្រប់គ្រងរមណីយដ្ឋានភ្នំព្រះរាជទ្រព្យ ត្រូវកំណត់ដោយអនុក្រឹត្យ ។

## ជំពូកទី ៣

## អវសានប្បញ្ញត្តិ

**មាត្រា ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍។

**មាត្រា ៦.-** នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

**ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា**

**ព្រះហស្តលេខា**

**នរោត្តម សីហនុ**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ

សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

ឧបសម្ព័ន្ធទី ១ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៨០

ចុះថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០១

## តារាងសម្រង់និយាមការនៃចំណុចព្រំប្រទល់ផ្នែកខាងក្រៅ របស់តំបន់អភិវឌ្ឍន៍សេដ្ឋកិច្ចទេសចរណ៍ (តំបន់២)

| ល.រ | X (E) | Y (N) |
|---|---|---|
| a | 474705.03 | 1304886.90 |
| b | 475180.99 | 1304309.39 |
| c | 475567.11 | 1394330.35 |
| d | 476211.78 | 1303127.94 |
| e | 476194.07 | 1302994.03 |
| f | 475968.68 | 1302920.21 |
| g | 476128.19 | 1302448.37 |
| h | 475556.83 | 1302381.38 |
| i | 475009.66 | 1302539.27 |
| j | 474742.69 | 1303305.68 |
| k | 474033.76 | 1304046.80 |
| l | 474033.69 | 1304255.43 |
| m | 474602.00 | 1304881.45 |

## តារាងសម្រង់និយាមការនៃចំណុចព្រំប្រទល់ផ្នែកខាងក្រៅ របស់តំបន់អភិរក្ស និង ថែរក្សាបរិស្ថានធម្មជាតិ (តំបន់៣)

| ល.រ | X (E) | Y (N) |
|---|---|---|
| A | 474435.05 | 1305460.34 |
| B | 474850.04 | 1305458.15 |
| C | 474847.31 | 1304940.15 |
| D | 475640.60 | 1304613.97 |
| E | 476393.97 | 1303542.98 |
| F | 476397.89 | 1302768.95 |
| G | 476183.87 | 1302766.08 |
| H | 476174.48 | 1302314.12 |
| I | 474929.42 | 1302304.69 |
| J | 473942.00 | 1303744.91 |
| K | 473948.32 | 1304944.89 |
| L | 474432.32 | 1304942.34 |

ឧបសម្ព័ន្ធទី ២ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥០១/១៨០ ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ ២០០១

